# រាជបណ្ឌិត្យសភាកម្ពុជា

## លទ្ធផលកិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ នៃក្រុមប្រឹក្សាជាតិភាសាខ្មែរ នៅខែមករា ឆ្នាំ២០១៨

( ចងក្រងដោយ៖ RAC Media; ប្រភពឯកសារ៖ កជភខ )

## ១-កិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ ថ្ងៃទី២ ខែមករា ឆ្នាំ២០១៨

ថ្ងៃអង្គារ ១រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី២ ខែមករា ឆ្នាំ២០១៨ ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត ជួរ គារី បានបន្តដឹកនាំប្រជុំពិនិត្យ ពិភាក្សា និងអនុម័តបច្ចេកសព្ទគណៈកម្មការទស្សនវិជ្ជា បានចំនួន០៣ពាក្យ ដូចខាងក្រោម៖

| | |
|---|---|
| **១- មនុស្សជាតិ**<br>**អ. humanity**<br>**បារ. humanité(f.)** | ភាពរួមនៃអម្បូរមនុស្សទាំងមូល។ គំនិតនេះចាប់ផ្ដើមដោយអ្នកអត់ធ្មត់និយមដែលតែងយល់ថា មនុស្សជាតិ ជាកម្មវត្ថុនៃការគោរពនៅក្នុងជីវិតប្រកបដោយសីលធម៌។ ដោយឡែក នៅក្នុងសតវត្សរ៍ទី២០ កាស្សីរ័រ (Cassirer) បានស្នើថា មនុស្សជាតិគួរត្រូវបានគេយល់ក្នុងក្របខណ្ឌនៃសកម្មភាពដែលនាំទៅដល់ស្នាដៃខាងវប្បធម៌និងប្រវត្តិសាស្ត្រ។ ស៊ីសេរ៉ូ (Cicero)និងសេណេកា(Seneca) បានបង្កើតពាក្យមនុស្សជាតិសម្គាល់ន័យថា ជាឧត្ដមគតិខាងសីលធម៌-សោភ័ណ ឬវិថីនៃជីវិត ជាគំនិតមួយ ដែលត្រូវបានគេធ្វើឱ្យរស់ឡើងវិញនៅក្នុងបុនសម័យ ឬសម័យកកើត ឡើងវិញ។<br>(ពាក្យនេះប្រើនៅក្នុងសីលវិជ្ជានិងសោភណវិជ្ជា) |
| **២-សាកលរូបី**<br>**អ. concrete universal**<br>**បារ. universel concret** | បច្ចេកសព្ទមួយដែលបង្ហាញដោយហេហ្គែល(Hegel) ដើម្បីកែតម្រូវទស្សនៈបុរាណដែលថា សាកលគឺអរូបីដោយផ្អែកទៅលើធម្មជាតិទូទៅនៃប្រភេទភាវៈមួយតាមរយៈអរូបីកម្ម។ ហេហ្គែល ជឿថា សាកលគឺជា ទម្រង់រូបីជាជាងអរូបី។ "សាកលពិត" មិនមែនគ្រាន់តែជាបណ្ដុំនៃលក្ខណៈ ទូទៅចំពោះវត្ថុមួយចំនួននោះទេ ប៉ុន្តែ វាជាការរៀបរាប់លម្អិត អំពីខ្លួនវា ឬការបញ្ជាក់យ៉ាងច្បាស់អំពីខ្លួនវា។ សាកលមិនមែនដាច់ចេញពីភាព ដោយឡែកនានាទេ ហើយវាក៏មិនមែនទៅហួសពីភាពដោយឡែកដែរ។ ផ្ទុយទៅវិញសាកលមានមកជាប់ជាមួយនឹងភាពដោយឡែកដែលជា កត្តាសំខាន់នៃភាពដោយឡែកទាំងនោះ។<br>(ពាក្យនេះគេប្រើក្នុងបរិបទអស្តិរូបវិជ្ជា)។ |
| **៣-ពូជសាសន៍និយម/ ពូជនិយម**<br>**អ. racism**<br>**បារ. racisme(m.)** | អំណះអំណាងមួយដែលថា មានឋានានុក្រមនៃសមត្ថភាព ឬតម្លៃ ដែលកំណត់ដោយជីវសាស្ត្រក្នុងចំណោមពូជផ្សេងៗគ្នា និងអះអាងដោយ ខុសឆ្គងថា ពូជទាបគួរត្រូវបានគ្រប់គ្រងដោយពូជខ្ពស់។ ជាទូទៅ ពូជ សាសន៍និយម/ពូជនិយម បង្កំឬជំរុញដោយការភ័យខ្លាចនិងការស្អប់ខ្ពើម ហើយដែលនាំទៅដល់អំពើហិង្សាឬអំពើប្រល័យពូជសាសន៍ទ្រង់ទ្រាយ ធំៗ។<br>ពាក្យនេះគេប្រើនៅក្នុងទស្សនវិជ្ជានយោបាយ)។) |

## ២-កិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ ថ្ងៃទី៣ ខែមករា ឆ្នាំ២០១៨

ថ្ងៃពុធ ២រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី៣ ខែមករា ឆ្នាំ២០១៨ ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្រោមអធបតីភាពឯកឧត្តមបណ្ឌិត ហ៊ាន សុខុម ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ បន្តប្រជុំអនុម័តបច្ចេកសព្ទគណៈកម្មការសុខាភិបាល បានចំនួន១៤៣ពាក្យ ដូចខាងក្រោម៖

| | |
|---|---|
| ១-ការលាងរបួស/អាប់ស្ទែស្យុង<br>អ. abstersion<br>បារ. abstersion (f.) | ការសម្អាតរបួសដោយប្រើឱសថលាងរបួស(abstergent)។ |
| ២-អកាល់គុយលី<br>អ. acalculia<br>បារ. acalculie(f.) | អសមត្ថភាពរបស់បុគ្គលក្នុងការគិតលេខ ដូចជា បូក ដក គុណ ចែក ជាដើម។ |
| ៣- អកាឌីយ៉ាក់<br>អ. acardiac<br>បារ. acardiaque (m.) | វិរូបភាពគ្មានបេះដូងពីកំណើត។ |
| ៤- អាក់សែ<br>អ. access<br>បារ. accès(m.) | អាការៈជំងឺកើតឡើងយ៉ាងទាន់ហន់ខ្លាំងក្លាដែលមានរយៈពេលខ្លីជាបន្តបន្ទាប់និងទៀងទាត់។ |
| ៥- ស្ត្រូក<br>អ. stroke / cerebrovascular accident<br>បារ.accident vasculaire cérébral (AVC)(m.) | ផលវិបាកស្រួចស្រាល់នៃខួរក្បាលបណ្ដាលមកពីគ្រោះថ្នាក់ ដោយស្ទៀតឬដាច់សរសៃឈាមក្នុងខួរក្បាលឬក្នុងស្រោមខួរក្បាលដែលបង្កជាកង្វះឈាមទៅចិញ្ចឹមខួរក្បាល។ |
| ៦- អសេហ្វាលី<br>អ. acephalia<br>បារ. acéphalie(f.) | វិរូបភាពគ្មានក្បាលមួយចំណែកឬទាំងមូលពីកំណើត។ |
| ៧- អាសេតូន<br>អ.acetone (ketone)<br>បារ. acétone(f.) | សារធាតុអាស៊ីដសរីរាង្គកើតឡើងដោយសារអុកស៊ីដកម្ម អាស៊ីដខ្លាញ់ក្នុងសរីរាង្គកាយដែលជាធម្មតាមានបរិមាណ តិចតួចនៅក្នុងឈាមនិងទឹកម្ងូត្រ។ |
| ៨- អាសេតូនេមី<br>អ. acetonaemia<br>បារ. acétonémie(f.) | វត្តមានអាសេតូននៅក្នុងឈាម។ |
| ៩- អាសេតូនូរី<br>អ. acetonuria<br>បារ. acétonurie(f.) | វត្តមានអាសេតូននៅក្នុងទឹកម្ងូត្រ។ |
| ១០- អកេលី<br>អ.acheilia<br>បារ. acheillie/ achélie/ achilie(f.) | វិរូបភាពគ្មានបបូរមាត់មួយផ្នែកឬទាំងមូលពីកំណើត។ |
| ១១- អកីរី<br>អ. acheiria<br>បារ.acheirie(f.) | វិរូបភាពគ្មានប្រអប់ដៃម្ខាងឬទាំងសងខាងពីកំណើត។ |

| | |
|---|---|
| ១២- អគីរ៉ូប៉ូឌី<br>អ. acheiropodia<br>បារ.acheiropodie(f.) | វិរូបភាពគ្មានប្រអប់ដៃនិងប្រអប់ជើងម្ខាងឬទាំងសងខាងពីកំណើត។ |
| ១៣- អក្លរីឌ្រី<br>អ. achlorhydria<br>បារ. achlorhydrie/<br>anachlorhydrie(f.) | អាការៈមិនប្រក្រតីដោយគ្មានអាស៊ីដក្លរីឌ្រិកក្នុងរសក្រពះ។ |
| ១៤- អកូលី<br>អ. acholia<br>បារ. acholie(f.) | អាការៈមិនប្រក្រតីរបស់ថ្លើមដែលគ្មានការបញ្ចេញទឹកប្រមាត់។ |

## ៣-កិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ ថ្ងៃទី៩ ខែមករា ឆ្នាំ២០១៨

ថ្ងៃអង្គារ ៨រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី៩ ខែមករា ឆ្នាំ២០១៨ ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត ជួរ គារី បានបន្តប្រជុំអនុម័តពាក្យគណៈកម្មការទស្សនវិជ្ជា បានចំនួន០៥ពាក្យ ដូចខាងក្រោម៖

| | |
|---|---|
| ១- យុត្តសង្គ្រាម<br>អ. just war<br>បារ.Juste la guerre | ទ្រឹស្ដីយុត្តសង្គ្រាមដំបូងបង្អស់ជាប់ពាក់ព័ន្ធទៅនឹងគំនិតរបស់និកាយ កាតូលិកដែលអះអាងថា ការប្រើកម្លាំង គឺជាអំពើត្រឹមត្រូវតាមច្បាប់សម្រាប់ ដាក់ទោសអ្នកប្រព្រឹត្តអាក្រក់ប្រឆាំងនឹងសាសនារបស់ខ្លួន។ បច្ចុប្បន្ន វាជា ប្រធានបទសំខាន់មួយនៅក្នុងទស្សនវិជ្ជានយោបាយ ដែលចាត់ទុកការប្រើប្រាស់ កម្លាំងសម្រាប់គោលបំណងខាងនយោបាយថាជារឿងត្រឹមត្រូវខាងសីលធម៌។<br>ជាធម្មតា ទ្រឹស្ដីយុត្តសង្គ្រាមពាក់ព័ន្ធនឹងលក្ខខណ្ឌពីរ ពោលគឺ មូលហេតុ ត្រឹមត្រូវចំពោះសង្គ្រាមនិងមធ្យោបាយត្រឹមត្រូវរបស់សង្គ្រាម។ បុព្វហេតុត្រឹមត្រូវ សំដៅយកការធ្វើសង្គ្រាមដើម្បីការពារព្រំដែនឆ្លើយតបទៅនឹងការ ឈ្លានពាន និងស្វែងរកសន្តិភាព។ មធ្យោបាយត្រឹមត្រូវ គឺសំដៅយកការប្រើប្រាស់អាវុធ ធម្មតាសម្រាប់ធ្វើសង្គ្រាមដោយជៀសវាង ការប្រើប្រាស់អាវុធមហាប្រល័យ ដូចជាអាវុធបរមាណូ អាវុធជីវសាស្ត្រ និងអាវុធគីមីជាដើម។ សង្គ្រាមយុត្តិធម៌ត្រូវតែផ្ដួចផ្ដើម ដឹកនាំ និងប្រកាស ជាផ្លូវការដោយអាជ្ញាធរធម្មានុរូប ត្រូវតែ " ប្រយុទ្ធដើម្បីបុព្វហេតុយុត្តិធម៌" ប្រកបដោយគោលបំណងត្រឹមត្រូវ និងត្រូវតែ ការពារនិងជៀសវាងការ សម្លាប់បុគ្គលិកយោធាដែលមិនប្រយុទ្ធ (គ្រូពេទ្យ បព្វជិត...) ជាពិសេសប្រជាជនដែលគ្មានកំហុស។<br>(ពាក្យនេះប្រើក្នុងបរិបទសីលវិជ្ជានិងទស្សនវិជ្ជានយោបាយ) |

| | |
|---|---|
| **២- សូហ្វីស**<br>អ. sophist<br>បារ. sophiste | កាលពីដំបូងពាក្យសូហ្វីសសំដៅយកមនុស្សដែលប្រកបដោយគតិបណ្ឌិត ដូចជា កវីនិពន្ធ អ្នកព្យាករ ព្រឹទ្ធាចារ្យប្រកបដោយភាពឈ្លាសវៃ។ ប៉ុន្តែនៅក្នុងសតវត្សរ៍ទី៥មុនគ្រិស្តសករាជ ពាក្យសូហ្វីស សំដៅយកបច្ចេកសព្ទពិសេស មួយដែលមានន័យថា គ្រូបង្រៀនជំនាញដែលបានដើរផ្សងព្រេងពីទីក្រុង មួយទៅទីក្រុងមួយ ដើម្បីបង្រៀនមុខវិជ្ជាជាច្រើនដែលមិនធ្លាប់មានពីមុនមក ដូចជា វោហារសាស្ត្រ ភាសាវិទ្យា ជាដើម ដែលយុវជនក្រិកត្រូវការជាចាំបាច់ ដើម្បីបញ្ចុះបញ្ចូលអ្នកនយោបាយ។ សូហ្វីសបានយកថ្លៃបង្រៀនពីសិស្ស ដែលមករៀនជាមួយពួកគេ។ នៅក្នុងពេលនោះ ពាក្យសូហ្វីសមិនមានន័យ អវិជ្ជមានឬន័យអាក្រក់ទេ។ ពួកសូហ្វីសមិនមែនចេញមកពីនិកាយណាមួយ ហើយភាគច្រើននៃពួកគេ ក៏មិនមែនជាទស្សនវិទូដែរ។ ក្នុងចំណោមពួក សូហ្វីសដែលល្បីល្បាញបំផុតមាន ប្រូតាហ្គោរ៉ាស(Protagoras) ហ្គ័រហ្ស៊ីយ៉ាស (Gorgias) ត្រាស៊ីម៉ាជុស(Thrasymachus) ប្រូឌីគុស(Prodicus) ហ៊ីប្យាស (Hippias)។<br>ក្រោយពីជំនាន់ពួកសូហ្វីសខាងលើមក ពាក្យសូហ្វីស មានអត្ថន័យ អវិជ្ជមានរហូតមកដល់បច្ចុប្បន្ន។ ការប្រែប្រួលដ៏ធំនេះ មកពីការឃោសនា ជំទាស់របស់ប្លាតុងនិងអារីស្តូត ដែលចោទពួកសូហ្វីសថាជាអ្នករកលុយពី ការបង្រៀនរបស់ពួកគេនិងយកតម្លៃខ្ពស់ក្នុងការបង្រៀនបច្ចេកទេសយកឈ្នះក្នុងការតស៊ូមតិ។ ពួកសូហ្វីសជាច្រើនជាគោលដៅចំអកនៅក្នុងអត្ថបទ សន្ទនារបស់ប្លាតុង ហើយក្រោយមក ពួកសូហ្វីសត្រូវបានញែកចេញពីអ្នក ប្រកបមុខវិជ្ជាខាងបញ្ញាដោយពិតប្រាកដ។ ប៉ុន្តែផ្តើមពីការខ្វះខាតខាង ព័ត៌មានសម្រាប់ដំណើរការពួកសូហ្វីសប្រៀបដូចជាអ្នករួមគ្នាបង្កើតចលនាសេរី ដែលបង្កជាភាពសង្ស័យក្នុងប្រពៃណីនិងក្នុងចំណុចខ្លះនៃការបំភ្លឺ។ ពួកសូហ្វីសបានរួមវិភាគទានដ៏សំខាន់នៅក្នុងប្រវត្តិសាស្ត្រនៃការគិតក្នុង ជំនាញវេយ្យាករណ៍និងទ្រឹស្តីភាសាវិទ្យា សីលធម៌និងទ្រឹស្តីនយោបាយទ្រឹស្តី អំពីធម្មជាតិនិងប្រភពរបស់មនុស្សនិងសង្គម។ ដោយគ្មានសំណេររបស់ សូហ្វីសណាម្នាក់នៅសល់ ដូច្នេះវាជាការលំបាកក្នុងការកែតម្រូវបុរេនិច្ឆ័យ ពីមុនដែលប្រឆាំងនឹងពួកសូហ្វីស។<br>(ពាក្យនេះគេប្រើក្នុងទស្សនវិជ្ជាក្រិកបុរាណសម័យ។) |

## ៤-កិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ ថ្ងៃទី១០ ខែមករា ឆ្នាំ២០១៨

ថ្ងៃពុធ ៩រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី១០ ខែមករា ឆ្នាំ២០១៨ ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត ហ៊ាន សុខុម បានបន្តប្រជុំពិនិត្យ និងអនុម័តបច្ចេកសព្ទគណៈកម្មការសុខាភិបាលបានចំនួន១០ពាក្យ ដូចខាងក្រោម៖

| | |
|---|---|
| **១- អកូលូរី**<br>អ. acholuria<br>បារ. acholurie(f.) | អាការៈមិនប្រក្រតីដោយគ្មានទឹកប្រមាត់ក្នុងទឹកមូត្រ។ |
| ២- អក្រូម៉ាស៊ី<br>អ. achromasia<br>បារ. achromasie(f.) | អាការៈមិនប្រក្រតីរបស់ស្បែកដែលបាត់ជាតិពណ៌។ |
| **៣- អក្រូម៉ាតុបស៊ី**<br>អ. achromatopsia<br>បារ. achromatopsie(f.) | អាការៈមិនប្រក្រតីរបស់ភ្នែកដែលមិនអាចញែកពណ៌បាន។ |

| | |
|---|---|
| **៤-អក្រូមី**<br>អ. achromia<br>បារ. achromie(f.) | ការថយចុះឬការបាត់ជាតិពណ៌របស់ស្បែក។ |
| **៥-អគីលី**<br>អ. achylia<br>បារ. achylie(f.) | អវត្តមានអាស៊ីដក្លរីឌ្រិកក្នុងរសក្រពះ។ |
| **៦-អាស៊ីដេមី**<br>អ. acidaemia<br>បារ. acidémie(f.) | ភាពចុះទាបជាងធម្មតានៃកម្រិតpH(៧,៤០)របស់ឈាម។ |
| **៧-អាស៊ីដូស**<br>អ. acidosis<br>បារ. acidose(f.) | អាការៈមិនប្រក្រតីដោយមានអតុល្យភាពអាស៊ីដ-បាសនៃប្លាស្មាក្នុងឈាម ដែលកម្រិត pH តូចជាង៧,៤០។ |
| **៨-អាស៊ីដួរី**<br>អ. aciduria<br>បារ. acidurie(f.) | វត្តមានអាស៊ីដច្រើនលើសលប់ក្នុងទឹកមូត្រ។ |
| **៩-អចលនា**<br>អ. akinesia<br>បារ.acinésie(f.)/ akinésie(f.) | អាការៈមិនប្រក្រតីដែលសាច់ដុំពុំអាចកន្ត្រាក់បាន។ |
| **១០-អកូរី**<br>អ. acoria<br>បារ. acorée/ acorie(f.) | វិរូបភាពគ្មានរន្ធប្រស្រីភ្នែកពីកំណើត។ |

## ៥-កិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៨

ថ្ងៃអង្គារ ១៥រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៨ ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត ជួរ គារី បន្តការប្រជុំពិនិត្យ និងអនុម័តបច្ចេកសព្ទគណៈកម្មការទស្សនវិជ្ជាបានចំនួន៤ពាក្យ ដូចខាងក្រោម៖

| | |
|---|---|
| **១-នវសេរីនិយម**<br>**អ. neoliberalism**<br>**បារ. néolibéralisme** | គំរូគោលនយោបាយមួយស្ដីអំពីការសិក្សាសង្គមនិងសេដ្ឋកិច្ច ដែលផ្ទេរការគ្រប់គ្រងវិស័យសេដ្ឋកិច្ចពីរដ្ឋទៅឯកជន។ នវសេរីនិយមមានប្រភពពីគោលការណ៍មូលដ្ឋាននៃសេដ្ឋកិច្ចនវក្លាស៊ិក(neoclassical economics) ដែលស្នើថា រដ្ឋាភិបាលត្រូវតែកម្រិតឱនភាពថវិកា ធ្វើកំណែទម្រង់ច្បាប់ពន្ធ ដើម្បីពង្រីកមូលដ្ឋានពន្ធ កាត់បន្ថយឱនភាពចំណាយ? កម្រិតគាំពារនិយម (limit protectionism) និងបើកចំហទីផ្សារទៅរកពាណិជ្ជកម្ម។<br>នវសេរីនិយមក៏ស្វែងរកការលុបចោលនូវអត្រាប្ដូរប្រាក់ថេរ/ដែលមិនផ្លាស់ប្ដូរ/ដែលមិនប្រែប្រួល/ដែលនៅនឹង/លំនឹងគាំទ្រការកាត់បន្ថយការ គ្រប់គ្រងរបស់រដ្ឋមកលើធុរកិច្ចអនុញ្ញាតឱ្យមានទ្រព្យសម្បត្តិឯកជននិងធ្វើឯកជននីយកម្មធុរកិច្ច។ |
| **២-អត្តស្នេហានិយម**<br>**អ. Narcissism/ Narcisism**<br>**បា. Narcissisme** | ការជក់ចិត្តនឹងខ្លួនឯងហួសប្រមាណ ការស្រឡាញ់ខ្លួនឯងហួសហេតុ មោទនភាពជ្រុលចំពោះខ្លួនឯង។<br>ពាក្យនេះមានប្រភពមកពីទេវកថាក្រិក រឿង**ណាគីសូស**(narkissos) ឬ **ណាស៊ីស៊ូស**(Narcissus)។ |

| | |
|---|---|
| **៣- លូធែនិយម**<br>**អ. Lutheranism**<br>**បា. Luthéranisme** | ទម្រង់ដំបូងនៃលទ្ធិប្រូតេស្តង់ដែលបង្កើតឡើងដោយ **ម៉ាទីន លូធែ** (Martin Luther1483-1546, German)នាសតវត្សរ៍ទី១៦ នៅប្រទេសអាល្លឺម៉ង់។<br>លទ្ធិនេះផ្តោតទៅលើការបង្រៀនរបស់ព្រះយេស៊ូគ្រិស្ត និងសង្កត់ធ្ងន់ទៅ លើជំនឿនិងសេចក្តីស្មោះត្រង់របស់បុគ្គលទៅលើអំណាចរួមរបស់សហគមន៍គ្រិស្តសាសនា។<br>លូធែនិយមសាយភាយដំបូងឆ្លងកាត់អឺរ៉ុបខាងជើង ជាពិសេសឆ្លងកាត់តំបន់**ស្កង់ឌីណាវី**(Scandinavia)បច្ចុប្បន្នលទ្ធិនេះត្រូវបានគេប្រតិបត្តិពាសពេញពិភពលោក។ |
| **៤- ប្រូតេស្តង់និយម**<br>**អ. Protestantism**<br>**បា. Protestantisme** | លទ្ធិមួយក្នុងចំណោមលទ្ធិសំខាន់ៗទាំង៣នៃគ្រិស្តសាសនា រួមមាន រ៉ូម៉ាំងកាតូលិកនិយម(Catholicism) អ័រតូដុកនិយម(Orthodoxy) និងប្រូតេស្តង់និយម(Protestantism)។<br>ប្រូតេស្តង់និយមបានចាប់ផ្តើមឡើងនៅសតវត្សរ៍ទី១៦ ជាចលនាមួយដើម្បីកែទម្រង់សហគមន៍គ្រិស្តសាសនានៅបស្ចិមប្រទេសដោយបង្កើតសហគមន៍ប្រូតេស្តង់ចេញពីរ៉ូម៉ាំងកាតូលិក។ គោលបំណងរបស់ពួកប្រូតេស្តង់និយម គឺស្រោចស្រង់ ជំនឿគ្រិស្តសាសនាឱ្យល្អដូចដើមឡើងវិញ។ ទន្ទឹមនឹងនេះពួកគេក៏បានរក្សាទុកនូវ អ្វីដែលពួកគេគិតថាមានតម្លៃហើយដែលបានអភិវឌ្ឍដោយពួករ៉ូម៉ាំងកាតូលិកនៅចន្លោះសតវត្សរ៍ទី៥ដល់ទី១៥។ |

## ៦-កិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៨

ថ្ងៃពុធ ១កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៨ ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត ហ៊ាន សុខុម បានបន្តប្រជុំពិនិត្យ និងអនុម័តបច្ចេកសព្ទគណៈកម្មការសុខាភិបាលបានចំនួន០៦ពាក្យ ដូចខាងក្រោម៖

| | |
|---|---|
| ១-អាគូម៉ែត្រ<br>អ.acoumeter<br>បារ. acoumètre(m.) | ឧបករណ៍វេជ្ជសាស្រ្តសម្រាប់វាស់សំឡេងដែលត្រចៀកអាចស្តាប់ឮ។ |
| ២- អាគូមេទ្រី<br>អ.acoumetry<br>បារ.acoumétrie(f.) | ការវាស់សំឡេងដែលត្រចៀកអាចស្តាប់ឮដោយប្រើអាគូម៉ែត្រ។ |
| ៣- អាគូហ្វែន<br>អ.tinnitus<br>បារ. acouphène(m.) | អាការៈមិនប្រក្រតីរបស់ត្រចៀកដែលហ៊ុំងហើយឮសំឡេង ប្លែកៗខុសពីសំឡេងរំញោចពីខាងក្រៅ។ |
| ៤- អាគូស្មាតាញ៉ូស៊ី<br>អ. acousmatagnosis<br>បារ. acousmatagnosie(f.) | ជំងឺថ្លង់ម្យ៉ាងដែលបណ្តាលមកពីប្រព័ន្ធសរសៃប្រសាទកណ្តាលមិនអាចចាប់ឬដឹងសំឡេងអ្វីមួយបានច្បាស់។ |
| ៥- អាក្រូសេហ្វាលី<br>អ. acrocephalia<br>បារ. acrocéphalie/hypsocéphalie(f.) | វិរូបភាពនៃឆ្អឹងលលាដ៍ក្បាលដោយផ្នែកខាងមុខនិងសងខាងមិនលូតលាស់ធ្វើឱ្យទ្រង់ទ្រាយក្បាលមានរាងសំប៉ែត ហើយឆ្អឹងលលាដ៍ខាងក្រោយរីវត្តពយទៅក្រោយនិងទៅលើ។ |
| ៦-អាក្រូស្យាណូស<br>អ. acrocyanosis<br>បារ. acrocyanose(f.) | អាការៈមិនប្រក្រតីរបស់ស្បែកដោយចុងដៃចុងជើងឡើងពណ៌ខៀវស្លេកជាប្រចាំ។ អាការៈនេះកម្រកើតមាននៅច្រមុះ ត្រចៀក ថ្ពាល់ និងផ្នែកខាងក្រោយនៃដើមដៃ។ |

## ៧-កិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៨

ថ្ងៃអង្គារ ៧កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្រោមអធិបតីភាពរបស់ឯកឧត្តមបណ្ឌិត ហ៊ាន សុខុម ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ បន្តការប្រជុំពិនិត្យ និងអនុម័តបច្ចេកសព្ទគណៈកម្មការទស្សនវិជ្ជាបានចំនួន៣ពាក្យ ដូចខាងក្រោម៖

| | |
|---|---|
| ១- ត្រីមូរ្តិ /ត្រីមូរតិ<br>អ.Trimurti<br>បារ.Trimurti | បញ្ញត្តិមួយដែលគេប្រើនៅក្នុងសាសនាហិណ្ឌូ សំដៅទៅលើអាទិទេព បីអង្គ គឺព្រះព្រហ្ម(អ្នកបង្កើតលោក) ' ព្រះវិស្ណុ/ព្រះនារាយណ៍(អ្នកការពារ និងថែរក្សាលោក) និងព្រះសិវៈ/ព្រះឥសូរ(អ្នកបំផ្លាញឬបង្កើតលោកឡើង វិញ) ហើយត្រូវបានគេធ្វើបដិរូបកម្មជាប្រជុំអាទិទេព។ នៅពេលដែល អាទិទេពទាំងពារបស់ត្រីមូរ្តិ/ត្រីមូរតិប្រែក្លាយទៅជាអវតារតែមួយ គេហៅថា ទត្តាត្រេយ។ |
| ២- ត្រីអង្គ<br>អ.Trinity<br>បារ.Trinité | បញ្ញត្តិមួយស្ដីពីអាទិទេពនៅក្នុងលទ្ធិគ្រិស្តសាសនា ដែលជឿថាអាទិទេពមានអត្ថិភាពជាអង្គបី គឺព្រះបិតា ព្រះរាជបុត្រា(ព្រះយេស៊ូគ្រិស្ត) និងព្រះ វិញ្ញាណបរិសុទ្ធ។ |
| ៣- ត្រីអង្គនិយម<br>អ.Trinitarianism<br>បារ.Trinitarianisme | លទ្ធិមួយនៅក្នុងគ្រិស្តសាសនាដែលជឿថា អាទិទេពមានអត្ថិភាពជា អង្គបី ប៉ុន្តែជាភាវៈតែមួយ។ អង្គទាំងបីនោះត្រូវបានគេយល់ថាមានអត្ថិភាព ជាព្រះបិតា ព្រះរាជបុត្រា(ព្រះយេស៊ូគ្រិស្ត) និងព្រះវិញ្ញាណបរិសុទ្ធហើយ អង្គនីមួយៗមានធម្មជាតិឬសារជាតិដូចគ្នា។ |

## ៨-កិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨

ថ្ងៃពុធ ៨កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត ជួរ គារី បានបន្តប្រជុំពិនិត្យ និងអនុម័តបច្ចេកសព្ទគណៈកម្មការសុខាភិបាលបានចំនួន១១ពាក្យ ដូចខាងក្រោម៖

| | |
|---|---|
| ១-អាក្រូឌីនី<br>អ. acrodynia<br>បារ. acrodynie(f.) | អាការៈឈឺចុកចាប់នៅប្រអប់ដៃនិងប្រអប់ជើងនៃកុមារដែលមានអាយុពី៦ទៅ៨ឆ្នាំ។ |
| ២- អាក្រូមេហ្គាលី<br>អ. Acromegaly<br>បារ. acromégalie (f.) | អាការៈរីកធំខុសធម្មតានៃក្បាល ច្រមុះ ត្រចៀក អណ្ដាត ព្រមទាំងឆ្អឹងចុងដៃចុងជើង និងមានគមកញ្ចឹងកធ្វើឱ្យឆ្អឹងទ្រូងរុញមកមុខ (cyphose cervico-dorsale avec saillie du sternum)។ |
| ៣-អាក្រូមេលី<br>អ.acromelia<br>បារ.acromélie(f.) | ផ្នែកខាងចុងដៃនិងជើង។ |

| | |
|---|---|
| ៤- អាក្រូមីគ្រី<br>អ. acromicria<br>បារ. acromicrie(f.) | អាការៈរួមតូចខុសប្រក្រតីនៃក្បាលចុងដៃនិងចុងជើងពីកំណើត។ |
| ៥- អាក្រូប៉ាទី<br>អ. acropathy<br>បារ. acropathie(f.) | ជំងឺដែលកើតមាននៅតែខាងចុងដៃ ចុងជើង និងក្បាល។ |
| ៦- អាក្រូប៉ូស្ទីត<br>អ. acroposthitis<br>បារ. acroposthite(f.) | អាការៈរលាកផ្នែកខាងចុងស្បែកគ្របក្បាលលិង្គ។ |
| ៧- អាក្រូសក្លេរ៉ូស<br>អ. acrosclerosis<br>បារ. acrosclérose(f.) | អាការៈក្រិនស្បែកផ្នែកខាងចុងដៃ ចុងជើង និងក្បាល។ |
| ៨-អាក្រូសាំងដាក់ទីលី<br>អ. acrosyndactyly<br>បារ. acrosyndactylie(f.) | វិរូបភាពដែលចុងម្រាមដៃឬចុងម្រាមជើងស្អិតជាប់គ្នាពីកំណើត។ |
| ៩- អាក់ទីនីត<br>អ. actinitis<br>បារ. actinite (f.) | អាការៈរលាកស្បែកដែលបង្កឡើងដោយរំភាយរស្មីព្រះអាទិត្យ។ |
| ១០- អាក់ទីណូមហារីក<br>អ. actinocancer<br>បារ. actinocancer(m.) | ជំងឺមហារីកស្បែកដែលបង្កឡើងដោយរំភាយរស្មីព្រះអាទិត្យ។ |
| ១១- អាក់ទីណូវិទ្យា<br>អ. actinology<br>បារ. actinologie(f.) | វិទ្យាសាស្ត្រសិក្សាអំពីផលប៉ះពាល់នៃរំភាយរស្មី ជាពិសេសកាំរស្មីស្វាយអ៊ុលត្រា(ultraviolet) ក្រហមអាំងហ្វ្រា (infr-arouge)...នៃព្រះអាទិត ្យក្នុងផ្នែកជីវវេជ្ជសាស្ត្រ។ |